Disability Rights California

*បណ្ដាញការពារ និង គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា (California)*

អាស័យដ្ឋានគេហទំព័រ: www.disabilityrightsca.org

ទូរស័ព្ទឥតគិតថ្លៃ: (800) 776-5746

TTY: (800) 719-5798

---

**# 1 អត្ថន័យសំខាន់ៗស្ដីពីការកាត់ខ្វង់ថវិកានៃរដ្ឋ (Fact Sheet) សម្រាប់កម្មវិធីផ្ដល់អត្ថប្រយោជន៍នានា – ថ្ងៃទី13 ខែសីហា ឆ្នាំ2009**

**ការកាត់ថវិកាសម្រាប់សេវា Medi-Cal**

ការផ្លាស់ប្ដូរទាំងនេះ មិនត្រូវបានគេធ្វើឡើងតាមរយៈយន្ដការនៃថវិការបស់រដ្ឋកាលីហ្វ័រញ៉ាឡើយ។
វិសោធនកម្មទាំងនេះ បានចាប់មានប្រសិទ្ធភាពកាលពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2009។

## របៀបដែលច្បាប់ត្រូវបានគេកែ

កម្មវិធី Medi-Cal ឈប់បន្តការបង់ប្រាក់សម្រាប់អត្ថប្រយោជន៍នានាដែលចុះខាងក្រោមនេះទៀតហើយសម្រាប់មនុស្សដែលមានអាយុចាប់ពី21ឆ្នាំឡើងទៅ។ កំណែច្បាប់នេះ មិនប៉ះពាល់ដល់មនុស្សដែលមានអាយុក្រោម21ឡើយ។ លើសពីនេះ ក៏នៅមានកំណែផ្នែកបច្ចេកទេសមួយចំនួនទៀតដែរដែលមិនរំពឹងថានឹងមានផលប៉ះពាល់ដោយផ្ទាល់ដល់អ្នកទទួលអត្ថប្រយោជន៍ពីកម្មវិធី Medi-Cal ដែរ។

## តើមានអត្ថប្រយោជន៍អ្វីខ្លះដែលកម្មវិធី Medi-Cal នឹងលែងទូទាត់ជំនួសទៀត?

ផ្នែកទី14131.10 នៃក្រមស្តីពីសុខមាលភាព និង ស្ថាប័ន និយាយថា កម្មវិធី Medi-Cal នឹងលែងទូទាត់ឲ្យចំពោះអត្ថប្រយោជន៍ និង សេវានានាដូចខាងក្រោមនេះសម្រាប់មនុស្សពេញវ័យភាគច្រើន (មានការលើកលែងមួយចំនួន។ សូមមើលខាងក្រោមនេះ):

- អត្ថប្រយោជន៍ផ្នែកទន្តពេទ្យ (ពេទ្យធ្មេញ)
- វិធីព្យាបាលការនិយា
- ការព្យាបាលជើង
- សវនាកម្ម
- ការធ្វើសរសៃ
- ការចាក់ម្ជុលវិទ្យាសាស្ត្រ
-ពេទ្យភ្នែក (ការពិនិត្យព្យាបាលភ្នែក [វេជ្ជបណ្ឌិតជំនាញផ្នែកភ្នែក] នឹងទទួលបានការបន្តធានារ៉ាប់រង)
- ពេទ្យចិត្តសាស្ត្រ (ពេទ្យវិកលចរិក និង សេវាទាំងអស់តាមរយៈកម្មវិធីសុខភាពខួរក្បាលថ្នាក់តំបន់ នឹងទទួលបានការបន្តធានារ៉ាប់រងតទៅទៀត)
- ក្រែម និង ការដុះលាង...

## តើមានអ្នកណាដែលអត្ថប្រយោជន៍របស់គេនឹងមិនប្រែប្រួលដែរទេ?

ប្រាកដណាស់។ អត្ថប្រយោជន៍នៃកម្មវិធី Medi-Cal ខាងលើនេះ និង សេវាកម្មនានា នឹងមិនប្រែប្រួលទេសម្រាប់មនុស្សដែល:

- មានអាយុក្រោម21ឆ្នាំ ឬ

- រស់នៅក្នុងលទ្ធភាពព្យាបាលដោយគ្រូពេទ្យជំនាញ (កម្រិត A ឬ B នេះ រួមមានលទ្ធភាពថែទាំព្យាបាលល្មម) ឬ

- មានគភ៌។ (ប្រសិនបើអ្នក មានគភ៌ អ្នកអាចបន្តទទួលអត្ថប្រយោជន៍ ទាក់ទងនឹងការមានគភ៌នេះបាន។ លើសពីនេះ អ្នកអាចទទួលបាន អត្ថប្រយោជន៍ផ្សេងៗទៀតដែលមានចុះខាងលើ ប្រយោជន៍រក្សានូវ លក្ខខ័ណ្ឌនានាដែលអាចមានការបណ្តាលឲ្យលំបាកជាច្រើនសម្រាប់ បញ្ហាមានគភ៌។ អត្ថប្រយោជន៍ទាំងនេះ មានជាអាទិ៍: ការពិនិត្យព្យាបាល សម្អាតធ្មេញ និង ការអញ្ចាញធ្មេញ។ អត្ថប្រយោជន៍ពីផ្នែកពេទ្យធ្មេញ និង ផ្សេងៗទៀត ក៏អាចនឹងមានរហូតដល់ 60ថ្ងៃ ក្រោយទារកបានកើត ដែរ) ឬ

- ការទទួលអត្ថប្រយោជន៍ តាមរយៈកម្មវិធីគាំពារកុមារនៅរដ្ឋកាលីហ្វ័រញ៉ា ឬ

- ការទទួលបានអត្ថប្រយោជន៍នានាតាមរយៈកម្មវិធី All-Inclusive Care សម្រាប់ជនចាស់ជរា។

## ប្រសិនបើខ្ញុំ មិនមានលក្ខណៈសម្បត្តិឆ្លើយតបទៅនឹងការរំពឹងទុកខាងលើនេះ តើខ្ញុំអាចនៅតែទទួលអត្ថប្រយោជន៍មួយចំនួនបានដែរឬទេ?

អ្នក នៅតែអាចទទួលបានអត្ថប្រយោជន៍មួយចំនួន ឬ ទាំងអស់ដែលត្រូវបានគេកាត់ហើយដែរ ដែលរួមមានសេវាពេទ្យធ្មេញជាក់លាក់ ប្រសិនបើអ្នកកំពុង:

- ទទួលបានអត្ថប្រយោជន៍នានាតាមរយៈកម្មវិធីសម្រាប់ជនពិការសេនេទិក (Genetically Handicapped Persons Program) ឬ

- ទទួលអត្ថប្រយោជន៍នានាតាមរយៈកម្មវិធីសុខភាពខួរក្បាលថ្នាក់តំបន់ ឬ

- ទទួលអត្ថប្រយោជន៍នានាតាមរយៈកម្មវិធីតំហែទាំសុខភាពផ្នែក B ឬ
- ទទួលអត្ថប្រយោជន៍នានាដោយផ្ទាល់ពីគ្រូពេទ្យម្នាក់។

អ្នក ត្រូវទាក់ទងគ្រូពេទ្យ ឬ ពេទ្យធ្មេញរបស់ខ្លួន ប្រសិនបើអ្នកមានចម្ងល់ណាមួយទាក់ទងនឹងបម្រែបម្រួលទាំងនេះ។

**តើមានអត្ថប្រយោជន៍ណាមួយដែលមានចុះនៅខាងលើនេះ ដែលខ្ញុំអាចនៅតែទទួលបានទេ ប្រសិនបើខ្ញុំមិនឆ្លើយតបទៅនឹងការរំពឹងទុកនេះ?**

ប្រាកដជាមាន:

- អ្នក អាចទទួលបាននូវអត្ថប្រយោជន៍នានាដែលមានចុះនៅខាងលើនេះ ប្រសិនបើលក្ខខ័ណ្ឌមានគភ៌កើតឡើង ហើយអត្ថប្រយោជន៍នេះ ចាំបាច់ត្រូវថែទាំចំពោះលក្ខខ័ណ្ឌនៃការមានគភ៌នេះ។
- អត្ថប្រយោជន៍សម្រាប់ការព្យាបាល និង វះកាត់មួយចំនួនដែលផ្តល់ដោយគ្រូពេទ្យធ្មេញ នឹងបន្តទទួលបានការធានារ៉ាប់រងតទៅទៀត។ សូមពិនិត្យមើលរកមើលជាមួយនឹងគ្រូពេទ្យធ្មេញរបស់អ្នកសម្រាប់ព័ត៌មានបន្ថែមទៀត។
- អត្ថប្រយោជន៍មួយចំនួននេះ អាចនឹងត្រូវបានគេផ្តល់ឲ្យនៅតាមគ្លីនិកសម្រាប់ទៅពិនិត្យ មណ្ឌលសុខភាពជំនាញព្យាបាលរបស់សហព័ន្ធ (FQHC) គ្លីនិកសុខភាពជនបទ (RHC) សេវាកម្មសុខភាពឥណ្ឌា (IHS) មណ្ឌលថែទាំសុខភាពសម្រាប់មនុស្សពេញវ័យនៅពេលថ្ងៃ ឬ តាមរយៈទីភ្នាក់ងារសុខភាពតាមផ្ទះ។ សូមសួរនាំគ្រូពេទ្យតំហែទាំសុខភាពបឋមរបស់អ្នកសម្រាប់ការបញ្ជូន។
- អត្ថប្រយោជន៍មួយចំនួនទាំងនេះ អាចនឹងត្រូវគេបន្តឲ្យ ប្រសិនបើបច្ចុប្បន្នអ្នកមិនកំពុងទទួលបានវា ឬ ប្រសិនបើអ្នកចេញពីក្រុមមួយដែលទទួលបានការលើកលែង ដូចជាអាយុក្រោម21ឆ្នាំ ទៅកាន់ក្រុមដែលមិនទទួលបានការ

លើកលែង។ សូមសួរនាំគ្រូពេទ្យតំបែហទាំសុខភាពរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

- ក្រសួងសុខាភិបាលថ្នាក់តំបន់របស់អ្នក អាចនឹងមានលទ្ធភាពផ្តល់ជូនអ្នកនូវអត្ថប្រយោជន៍មួយចំនួន មិនទទួលបានការធានារ៉ាប់រងដោយកម្មវិធី Medi-Cal តទៅទៀតទេ។

## តើខ្ញុំ អាចទៅទាក់ទងបាននៅទីណាខ្លះ សម្រាប់ព័ត៌មានបន្ថែម?

សូមមើល **http://www.dhcs.ca.gov/services/medi-cal/Pages/Benefits.aspx**
ប្រសិនបើអ្នក មានចម្ងល់លើសពីនេះ ពាក់ព័ន្ធនឹងកំណែទាំងនេះ អ្នកក៏អាចទូរស័ព្ទទាក់ទងទៅផ្នែកទំនាក់ទំនងអ្នកទទួលអត្ថប្រយោជន៍នៃកម្មវិធី Medi-Cal តាមរយៈទូរស័ព្ទដែលមានលេខ: **1-888-284-0623**។

## តើខ្ញុំ អាចស្នើសុំឲ្យមានសវនាការមួយបានទេ ប្រសិនបើខ្ញុំមិនយល់ស្របទៅនឹងកំណែច្បាប់ទាំងនេះ?

អ្នក មានសិទ្ធិស្នើសុំឲ្យមានសវនាការមួយបាន ប្រសិនបើអ្នកគិតថាច្បាប់នេះ មិនកំពុងត្រូវបានគេប្រើប្រាស់ត្រឹមត្រូវចំពោះអ្នក។ ឧទាហរណ៍: ប្រសិនបើអ្នកគិតថាអ្នកនៅមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬ សិទ្ធិសម្រាប់អត្ថប្រយោជន៍នេះ ដែលត្រូវបានគេកាត់រួចហើយ ដោយសារអ្នកមានសិទ្ធិសម្រាប់ការលើកលែងក្នុងចំណោមនៃការលើកលែងនានា ប៉ុន្តែថ្នាក់តំបន់នៅតែកំពុងធ្វើការកាត់អត្ថប្រយោជន៍អ្នកទៀតនោះ អ្នកមានសិទ្ធិស្នើរសុំឲ្យមានសវនាការសើរើឡើងវិញមួយបាន។ សូមមេត្តាទាក់ទង DRC ប្រសិនបើអ្នកគិតថាការកាត់

ទាំងនេះ នឹងជម្រុញឲ្យអ្នកចូលទៅក្នុងបញ្ហាច្បាប់មួយដើម្បីយើងអាចនឹងកំណត់មើលថាតើ យើងខ្ញុំមានលទ្ធភាពជួយដល់អ្នកបានដែរឬអត់។

**តើរហូតមកទល់ពេលនេះ មានគេដាក់បណ្តឹងផ្លូវច្បាប់ណាមួយហើយឬនៅ?**

មានមេធាវីការពារក្តីជាច្រើន បានដាក់ពាក្យបណ្តឹងផ្លូវច្បាប់នៅឯតុលាការសាលាដំបូងសហព័ន្ធដើម្បីបញ្ឈប់នូវការកាត់អត្ថប្រយោជន៍ទាំងនេះ។ សំណុំរឿងនេះ គឺមានលេខ C-09-02307 EMC ហើយ (តាមកាលបរិច្ឆេទនៃឯកសារនេះ) ត្រូវបានបង្កើតឡើងសម្រាប់សវនាការសើរើមួយនៅថ្ងៃទី5 ខែសីហា ឆ្នាំ2009 នៅតំបន់កាលីហ្វ័រញ៉ាភាគខាងជើង ចំពោះមុខចៅក្រម Judge Edward M. Chen។ ដោយសារថា ព័ត៌មានច្រើនជាងនេះដែលអាចរកបានស្តីពីបណ្តឹងផ្លូវច្បាប់នេះ DRC នឹងចុះផ្សាយបន្ថែមទៀតអំពីព័ត៌មាននេះនៅលើគេហទំព័ររបស់ខ្លួន www.disabilityrightsca.org។